ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៦៧០ អក
ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០
សាលក្រមព្រហ្មទណ្ឌលេខ: ០១២ "ខ"
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

# សាលក្រមព្រហ្មទណ្ឌ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ០២រសៀល ដោយមានសមាសភាពចូលរួម ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

### មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុចិន្តា ។

### ដើម្បីជំនុំជម្រះ

-លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៦៧០ អក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted] គីមសៀន ភេទប្រុស អាយុ ៣៦ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មុខរបរ អាជីវករ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សេង "រ" ម្តាយឈ្មោះ [redacted] មិត់ "រ" មានប្រពន្ធឈ្មោះ [redacted] សោភ័ណ្ឌ "រ" មានកូន ០៤ នាក់ ជានីតិជន ទោសពីមុនៈគ្មាន ។ (ឃុំខ្លួនថ្ងៃទី២២.០៤.២០)

ជាប់ចោទពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្ដា ភេទស្រី អាយុ ៤១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មេផ្ទះ មានទីលំនៅបច្ចុប្បន្ន នៅភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

-បានឃើញ របាយការណ៍សុប លេខ៖ ៨១ /២០ ដក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ របស់មន្ត្រីនគរបាលយុត្តិធម៌ ការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៖ ៤៩៧ ដកសស ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ៖ ១៦០៧ ដកបឃខ/២០ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ១១០១ ដកសព ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៖ ១១៤៧ កសកដ/២០ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាបង្គាប់ឱ្យរក្សាទុកជនត្រូវចោទនៅជាប់ឃុំបណ្ដោះអាសន្នលេខ៖ ១៣៤៦ កដរជឃប/២០ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ១២៧៦ ដកចត/២០ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទដូចតទៅ ៖**

កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ មានករណី "រំលោភលើទំនុកចិត្ត" កើតឡើងនៅចំណុចភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] គីមសៀន បានជួលគ្រឿងចក្រ (អេស្កាវ៉ាទ័រ) ពីជនរងគ្រោះឈ្មោះ [redacted] សុចិន្ដា ភេទស្រី អាយុ ៤០ឆ្នាំ ដើម្បីយកទៅឈូសឆាយដី កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ ដោយជួលក្នុងតម្លៃ ៤០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុងមួយខែ លុះរហូតដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ជនជាប់ចោទបានឈូសឆាយដីមួយកន្លែង ហើយត្រូវបានសមត្ថកិច្ចខេត្តស្ទឹងត្រែង ចុះឃាត់អេស្កាវ៉ាទ័រមករក្សាទុក ។ បន្ទាប់ពីសមត្ថកិច្ចធ្វើការឃាត់អេស្កាវ៉ាទ័រ រួចជនជាប់ចោទតែងតែគេចវេសមិនព្រមចូលមកធ្វើការដោះស្រាយហើយរត់គេចខ្លួនបាត់ ។ ក្រោយពីជនរងគ្រោះបានដាក់ពាក្យបណ្ដឹងសមត្ថកិច្ចបានធ្វើការស្វែងរកចាប់ខ្លួន ជនជាប់ចោទបាន នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ រួចធ្វើការបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្តកណ្ដាល ដើម្បីចាត់ការតាមនីតិវិធីតែម្ដង ។ ជនជាប់ចោទមិនបានបង់ប្រាក់ថ្លៃឈ្នួលអេស្កាវ៉ាទ័រ មកឱ្យជនរងគ្រោះចាប់តាំងពីពេលដែលសមត្ថកិច្ចឃាត់ទុកអេស្កាវ៉ាទ័រ មកឱ្យជនរងគ្រោះចាត់តាំងពីពេលដែលសមត្ថកិច្ចឃាត់ទុកមកម្លេះ ។

## ឆាពេលសមនាភារ

១-ជនជាប់ចោទឈ្មោះ [redacted] គីមសៀន បានឆ្លើយថា ៖ កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ៣ រសៀល ខ្លួនបានទៅជួលគ្រឿងចក្រ (អេស្កាវ៉ាទ័រ)ចំនួន ០១ គ្រឿង ដោយជួលពីឈ្មោះ [redacted] សុចិន្តា ដោយជួលក្នុងមួយខែ ៤០០០ (បួនពាន់) ដុល្លារអាមេរិក ដោយជួលចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១៩ ដោយនៅអំឡុងពេលដែលខ្លួនជួលគ្រឿងចក្រនេះ គ្រឿងចក្ររបស់ខ្លួនក៏ត្រូវបានសមត្ថកិច្ចចាប់ឃាត់ទុកយកមករក្សាទុកនៅទីបញ្ជាការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ដោយសារខ្លួនបានឈូសឆាយ និងកាយចំដីព្រៃរបស់រដ្ឋ ហើយខ្លួនបានតេទូរស័ព្ទទៅម្ចាស់គ្រឿងចក្រ ដោយប្រាប់គាត់ថាគ្រឿងចក្រត្រូវបានគេដកហូតយកមករក្សាទុក នៅទីបញ្ជាការកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង បាត់ហើយ ហើយខ្លួនបានចូលមកដោះស្រាយ ប៉ុន្តែពុំជោគជ័យ ។ លុះក្រោយមកទៀតម្ចាស់គ្រឿងចក្រឈ្មោះ [redacted] សុចិន្តា ចេះតែរករឿង និងដេរខ្លួនច្រើនលើកច្រើនសារតាមទូរស័ព្ទ ខ្លួនក៏បានរត់គេចខ្លួនមកស្នាក់នៅជាមួយប្រពន្ធកូនរបស់ខ្លួននៅភូមិព្រែកតាកែវ២ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ហើយចាប់ពីពេលនោះមក ខ្លួនពុំបានបង់ប្រាក់ឈ្នួលទៅឱ្យម្ចាស់គ្រឿងចក្រឈ្មោះ [redacted] សុចិន្តា ទៀតនោះទេ លុះក្រោយមកម្ចាស់គ្រឿងចក្រក៏បានទៅលោះយកគ្រឿងចក្រដែលខ្លួនបានជួលនោះពីសមត្ថកិច្ចយកមកវិញ ។ លុះមកដល់ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល ក៏ស្រាប់តែសមត្ថកិច្ចបានចុះមកធ្វើការសាកសួរ និងបានធ្វើការឃាត់ខ្លួននៅពេលនោះតែម្តង ។ ចំពោះការទាមទាររបស់ជនរងគ្រោះ ចំពោះថ្លៃលោះគ្រឿងចក្រ និងថ្លៃឈ្នួល គឺខ្លួនសុំបដិសេធចំពោះការទាមទាររបស់គាត់ ដោយសារនៅអំឡុងពេលដែលខ្លួនបានជួលគ្រឿងចក្រពីគាត់ គឺគ្រឿងចក្រត្រូវបានសមត្ថកិច្ចដកហូត ហើយខ្លួនបានជួលគាត់ពុំទាន់ចប់ថ្ងៃនៅឡើយ ។ ចំពោះប្រាក់ដែលខ្លួនជំពាក់ម្ចាស់គ្រឿងចក្រ គឺខ្លួនសុំសងឱ្យទៅម្ចាស់គ្រឿងចក្រចំនួន ៣.០០០ (បីពាន់) ដុល្លារអាមេរិក គឺថ្លៃដែលម្ចាស់គ្រឿងចក្របានទៅលោះយកគ្រឿងចក្រពីសមត្ថកិច្ចមកវិញ ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ សុំតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

២-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្តា បានឆ្លើយថា៖ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ៣ រសៀល ពេលនោះឈ្មោះ [redacted] គីមសៀន បានមកផ្ទះខ្លួន និងបានសុំជួលគ្រឿងចក្រ អេស្កាវ៉ាទ័រ ចំនួន ០១ (មួយ) គ្រឿង ពីខ្លួនដើម្បីយកទៅកាយព្រំដី និងជីកស្រះ ដែលស្ថិតនៅ ភូមិសាឡៅ ឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ដោយឈ្មោះ [redacted] គីមសៀន បានអះអាងថា ដីដែលត្រូវកាយព្រំនោះ គឺជាដីស្របច្បាប់មានប្លង់ត្រឹមត្រូវ ហើយខ្លួនបានព្រមជួលគ្រឿងចក្រ អេស្កាវ៉ាទ័រ ចំនួន ០១ (មួយ) គ្រឿង ទៅឱ្យឈ្មោះ [redacted] គីមសៀន ដោយខ្លួនបានជួលទៅឱ្យគាត់ក្នុងតម្លៃ ៤០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុង ០១ ខែ ដោយបានធ្វើកិច្ចសន្យាជួលគ្រឿងចក្រពីខ្លួន ដោយជួលចាប់ពីថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៩ តទៅដោយពុំបានកំណត់រយៈពេលនោះទេ ហើយឈ្មោះ [redacted] គីមសៀន នេះបានជួលគ្រឿងចក្រ អេស្កាវ៉ាទ័រ និងបង់ប្រាក់ឈ្នួលមកឱ្យខ្លួនបានចំនួនតែ ៤ ខែ តែប៉ុណ្ណោះ ។ លុះមកដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ [redacted] គីមសៀន មិនបានបង់



Scanned with CamScanner

ប្រាក់ថ្លៃឈ្នួលជួលអេស្កាវ៉ាទ័រ មកឱ្យខ្លួននោះទេ ស្រាប់តែមកដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ខ្លួនក៏បានទទួលដំណឹងពីម្ចាស់ផ្ទះដែលមានឈ្មោះ [redacted] គឹមសៀន បានយកគ្រឿងចក្រទៅធ្វើ គេមកប្រាប់ខ្លួនថា មានកម្លាំងកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង បានចាប់យកគ្រឿងចក្រអេស្កាវ៉ាទ័រ របស់ខ្លួនយកទៅបាត់ហើយ ហើយគ្រឿងចក្ររបស់ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ទុកនៅកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង អស់រយៈពេល ៦ខែ ហើយខ្លួនបានទំនាក់ទំនងទៅឈ្មោះ [redacted] គឹមសៀន ឱ្យចូលខ្លួនមកដោះស្រាយចំពោះមុខច្បាប់ ប៉ុន្តែឈ្មោះ ខាងលើបានគេចវេសមិនព្រមចូលខ្លួនមកដោះស្រាយជាមួយខ្លួននោះទេ ។ លុះក្រោយមកខ្លួនបានដាក់ពាក្យបណ្តឹងដោយប្តឹងពីឈ្មោះ [redacted] គឹមសៀន ពីបទ៖ រំលោភលើទំនុកចិត្ត តែម្តង ។ ខ្លួនសុំទាមទារសំណងជម្ងឺចិត្តពីឈ្មោះ [redacted] គឹមសៀន ចំនួន ៨៤,០០០ (ប្រាំបីម៉ឺនបួនពាន់) ដុល្លារអាមេរិក និងសុំឱ្យតុលាការផ្តន្ទាទោសជននេះទៅតាមច្បាប់ ។

៣-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទគឺមានចេតនាទុច្ចរិតក្នុងការជួលគ្រឿងចក្រពីកូនក្តីខ្លួន ដោយប្រាប់កូនក្តីខ្លួនថា ជួលទៅកាយព្រំដី និងជីកស្រះ ព្រមទាំងដីដែលមានច្បាប់ និងប្លង់ត្រឹមត្រូវ ទើបកូនក្តីខ្លួនព្រមជួលឱ្យ តែតាមពិតជនជាប់ចោទបានយកគ្រឿងចក្រដែលជួលពីកូនក្តីខ្លួន ទៅកាប់គាស់កាយដីព្រៃរបស់រដ្ឋ ហើយក៏ត្រូវបានកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ចាប់ឃាត់ទុក ។ ចំណែកជនជាប់ចោទបានរត់គេចខ្លួនបាត់ ដោយមិនចេញមុខដោះស្រាយជាមួយកូនក្តីខ្លួនឡើយ និងមិនបានបង់ប្រាក់ថ្លៃឈ្នួលជួលគ្រឿងចក្រផងដែរ ។ អំពើរបស់ជនជាប់ចោទបានធ្វើឱ្យកូនក្តីខ្លួនខាតបង់ពេលវេលា និងប្រាក់កាសជាច្រើន ដូច្នេះខ្លួនស្នើសុំតុលាការមេត្តាសម្រេចតាមការទាមទាររបស់កូនក្តីខ្លួន ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ក៏ដូចជាការពិនិត្យឯកសារនៅក្នុងសំណុំរឿង សូមលោកចៅក្រមពិនិត្យពិចារណា តើសំណុំរឿងនេះ ជាសំណុំរឿងរដ្ឋប្បវេណី ឬជាសំណុំរឿងព្រហ្មទណ្ឌ ពីព្រោះរឿងដែលកើតឡើង គឺកើតចេញពីកិច្ចសន្យាជួលគ្រឿងចក្រ រវាងជនជាប់ចោទ និងដើមបណ្តឹង ។ ឯរឿងព្រហ្មទណ្ឌ គឺជនជាប់ចោទបានយកគ្រឿងចក្រដែលជួលពីដើមបណ្តឹងទៅឈូសឆាយដីរបស់រដ្ឋ ដូច្នេះតំណាងអយ្យការស្នើសុំលោកចៅក្រមពិនិត្យសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## ***សាលាដំបូងខេត្តកណ្តាល***
## ***យល់ឃើញថា***

១-កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ មានករណី “រំលោភលើទំនុកចិត្ត” កើតឡើងនៅចំនុចភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] គីមសៀន បានជួលគ្រឿងចក្រ (អស្កាវ៉ាទ័រ) ពីជនរងគ្រោះឈ្មោះ [redacted] សុចិន្តា ភេទស្រី អាយុ ៥០ឆ្នាំ ដើម្បីយកទៅឈូសឆាយដី កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ ដោយជួលក្នុងតម្លៃ ៤០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុងមួយខែ លុះរហូតដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ជនជាប់ចោទបានឈូសឆាយដីមួយកន្លែង ហើយត្រូវបានសមត្ថកិច្ចខេត្តស្ទឹងត្រែងចុះឃាត់អេស្កាវ៉ាទ័រ មករក្សាទុក ។ បន្ទាប់ពីសមត្ថកិច្ចធ្វើការឃាត់អេស្កាវ៉ាទ័រ រួចជនជាប់ចោទតែងតែគេចវេសមិនព្រមចូលមកធ្វើការដោះស្រាយហើយរត់គេចខ្លួនបាត់ ។ ក្រោយពីជនរងគ្រោះបានដាក់ពាក្យបណ្តឹងហើយ សមត្ថកិច្ចបានធ្វើការស្វែងរកចាប់ខ្លួនជនជាប់ចោទបាន នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ រួចធ្វើការបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធីតែម្តង ។ ជនជាប់ចោទមិនបានបង់ប្រាក់ថ្លៃឈ្នួលអេស្កាវ៉ាទ័រមកឱ្យជនរងគ្រោះចាប់តាំងពីពេលដែលសមត្ថកិច្ចឃាត់ទុកអេស្កាវ៉ាទ័រ មកម្លេះ ។

២-ជនជាប់ចោទឈ្មោះ [redacted] គីមសៀន ជានីតិជនមានស្មារតីល្អគ្រប់គ្រាន់ដែលអាចដឹង និងទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] គីមសៀន បានឆ្លើយថា៖ ខ្លួនពិតជាបានជួលគ្រឿងចក្រពីម្ចាស់គ្រឿងចក្រឈ្មោះ [redacted] សុចិន្តា ដោយមានចុះកិច្ចសន្យាជួលមិនកំណត់អំឡុងពេល ដោយគិតតម្លៃថ្លៃឈ្នួល ៤០០០ (បួនពាន់) ដុល្លារអាមេរិក ដោយគិតចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ តទៅ ដោយពុំបានកំណត់រយៈពេលបញ្ចប់នោះទេ។ លុះដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ នៅក្នុងអំឡុងពេលជួលនេះ សមត្ថកិច្ច ក៏បានឃាត់គ្រឿងចក្រយកទៅរក្សាទុកនៅកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ដោយសារខ្លួនបានឈូសឆាយ និងកាយចំដីរបស់រដ្ឋ ។ ចាប់តាំងពីពេលនោះមកខ្លួនពុំបានបង់ថ្លៃឈ្នួលទៅឱ្យម្ចាស់គ្រឿងចក្រនោះទេ ។ ចម្លើយនេះបើផ្ទៀបទៅនឹងឯកសារនានាដែលមន្ត្រីនគរបាលយុត្តិធម៌ប្រមូលបាន, ផ្ទៀបនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ផ្ទៀបនឹងឯកសារជាភស្តុតាងនានា ដែលមាននៅក្នុងសំណុំរឿង ឃើញថាមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] គីមសៀន ពិតជាបានប្រព្រឹត្តអំពើ**រំលោភលើទំនុកចិត្ត** ពិតប្រាកដមែន ។

៤- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្តា បានឆ្លើយថា៖ ខ្លួនពិតជាបានឱ្យជនជាប់ចោទជួលគ្រឿងចក្រ(អេស្កាវ៉ាទ័រ) ប្រាកដមែន ដោយធ្វើកិច្ចសន្យាជួលក្នុងតម្លៃថ្លៃឈ្នួល ៤០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុង ០១ខែ ដោយគិតចាប់ពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ តទៅ ដោយពុំបានកំណត់រយៈពេលបញ្ចប់នោះទេ ហើយជនជាប់ចោទបានបង់ប្រាក់ថ្លៃឈ្នួលមកឱ្យខ្លួនបានចំនួន ០៤ខែ តែប៉ុណ្ណោះ ។ លុះមកដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ជនជាប់ចោទពុំបានបង់ថ្លៃឈ្នួលជួលគ្រឿងចក្រ(អេស្កាវ៉ាទ័រ)មកឱ្យខ្លួន

នោះទេ។ ស្រាប់តែមកដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ខ្លួនបានទទួលដំណឹងថា គ្រឿងចក្រ(អេស្កាវ៉ាទ័រ) របស់ខ្លួនត្រូវបានសមត្ថកិច្ចកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ធ្វើការឃាត់ទុកអស់រយៈពេល ០៦ខែ ចម្លើយនេះបើធៀបនឹងចម្លើយជនជាប់ចោទ ឃើញថាមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែល តំណាងអយ្យការធ្វើការចោទប្រកាន់ អាចឲ្យតុលាការជឿបាន ព្រោះស្របទៅនិងឯកសារភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿង ។

៥-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុកល្បាណ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បាន ឆ្លើយថា នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ [redacted] គីមសៀន ភេទប្រុស អាយុ ៣៥ឆ្នាំ ដែលមានទីលំនៅ ភូមិសំបូរ ស្រុកល្វាឯក បានទៅជួលគ្រឿងចក្រពីឈ្មោះ [redacted] សុចិន្តា ភេទស្រី អាយុ ៤០ ឆ្នាំដែលមានទីលំនៅ ភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី មួយគ្រឿងម៉ាក អេស្កាវ៉ាទ័រ ក្នុងតម្លៃ ៤០០០ (បួនពាន់) ដុល្លារអាមេរិក ក្នុង ០១ ខែ ជួលរយៈពេលគ្មានកំណត់ដើម្បីយកទៅកាយព្រំដី និងជីកស្រះ ដែល ស្ថិតនៅភូមិសាឡៅ ឃុំអន្លង់ជ្រៃ ស្រុកខាឡាបរិវ៉ាត ខេត្តស្ទឹងត្រែង ក្រោយពីនិយាយគ្នារួចក៏បានធ្វើកិច្ចសន្យា ជួលគ្រឿងចក្រនេះ ដែលមានលក្ខខណ្ឌប្រាំចំនុច ១.គ្រឿងចក្រធ្វើការងារមួយថ្ងៃ ៨ ម៉ោង ,២.ភាគីអ្នកជួល ធានាទទួលខុសត្រូវនៅសុវត្ថិភាពគ្រឿងចក្រ .បើមានបញ្ហាខុសបច្ចេកទេសគ្រឿងចក្រអ្នកជួលត្រូវទទួលខុស ត្រូវចំពោះមុខច្បាប់ ,៣.ប្រើតាមលក្ខណៈបច្ចេកទេសគ្រឿងចក្រ,៤.ការដឹកជញ្ជូនគ្រឿងចក្រចូលការដ្ឋានជា បន្ទុករបស់ភាគីអ្នកជួល, ៥.ភាគីអ្នកជួលគ្រឿងចក្រទទួលខុសត្រូវម្ហូបអាហារបីពេលក្នុងមួយថ្ងៃរបស់តៃកុង គ្រឿងចក្រ ។ ក្រោយពីធ្វើកិច្ចសន្យាជួលគ្រឿងចក្រដូចខាងលើមក ម្ចាស់គ្រឿងចក្រឈ្មោះ [redacted] សុចិន្តា និង អ្នកជួលឈ្មោះ [redacted] គីមសៀន និងសាក្សីដឹងឮ បានព្រមព្រៀងឯកភាពគ្នាផ្តិតមេដៃលើកិច្ចសន្យានោះទុកជាភ ស្តុតាងស្រាប់ ។ លុះដល់ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ ឈ្មោះ [redacted] គីមសៀន បានយកគ្រឿងចក្រនេះ ទៅ ឈូសឆាយលើដីដែលអាជ្ញាធរហាមឃាត់ ហើយក៏ត្រូវកងរាជអាវុធហត្ថខេត្តស្ទឹងត្រែង ចុះធ្វើការហាមឃាត់ ព្រមទាំងដកហូតគ្រឿងចក្រ ទៅរក្សាទុក ប៉ុន្តែឈ្មោះ [redacted] គីមសៀន មិនព្រមគោរពតាមកិច្ចសន្យាខាងលើ នេះទេ និងថែមគេចខ្លួនបាត់ទៀតផង ធ្វើឱ្យម្ចាស់គ្រឿងចក្រឈ្មោះ [redacted] សុចិន្តា ទៅប្រឈមមុខដោះស្រាយ និងយកគ្រឿងចក្ររបស់ខ្លួនមកវិញក៏បានទូរស័ព្ទហៅឈ្មោះ [redacted] គីមសៀន ទៅនិយាយគ្នាធ្វើការដោះស្រាយ ប៉ុន្តែឈ្មោះ [redacted] គីមសៀន មិនព្រមលើកទូរស័ព្ទទៀតផង តាមចម្លើយសាក្សីដែលបានឆ្លើយនេះបើធៀបនឹង ចម្លើយជនជាប់ចោទ នឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ធៀបនឹងឯកសារនានាដែលមាននៅក្នុងសំណុំរឿង ឃើញថាមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដែលអាចឲ្យតុលាការជឿបានថា កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ ២០២០ ពិតជាមានអំពើ រំលោភលើទំនុកចិត្ត ពិតប្រាកដមែន ។

៦-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន មានលក្ខណៈសមហេតុផលមួយ ចំនួន អាចឲ្យតុលាការយកមកពិនិត្យ និងសម្រេចតាមសភាពជាក់ស្តែង ។

៧-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន មានលក្ខណៈសមហេតុផលមួយចំនួន អាចឱ្យតុលាការទទួលយកមកពិនិត្យពិចារណាតាមសភាពជាក់ស្តែង ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គីមសៀន ភេទប្រុស អាយុ ៣៦ឆ្នាំ ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី កាលពីថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩១ និង មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៩-វត្ថុតាងរួមមាន៖

-កាបូបយួរដៃចំនួន ០១ (មួយ) ពណ៌សូកូឡា

-ទូរស័ព្ទដៃចំនួន ០១ (មួយ) ម៉ាក VIVO ពណ៌ខ្មៅលាយខៀវ

-អត្តសញ្ញាណប័ណ្ណចំនួន ០១ (មួយ) សន្លឹក របស់ឈ្មោះ [redacted] គីមសៀន

-កាតគ្រីម៉ូតូចំនួន ០១ (មួយ) សន្លឹក ផ្លាកលេខ កំពង់ធំ 1A-1499 កម្មសិទ្ធឈ្មោះ [redacted] ប៊ុនហុក

-កាតធនាគារអេស៊ីលីដាចំនួន ០១ (មួយ) សន្លឹក ឈ្មោះ SENG KOEHSEAN

តុលាការគប្បីប្រគល់ឱ្យម្ចាស់ដើមវិញ ស្របតាមបញ្ញត្តិមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្តា បានទាមទារសំណងជម្ងឺចិត្ត ចំនួន ៨៤,០០០ (ប្រាំបីម៉ឺនបួនពាន់) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] គីមសៀន តែតុលាការពិនិត្យឃើញថា ជនជាប់ចោទខក ខានមិនបានបង់ប្រាក់ថ្លៃឈ្នួលឱ្យដើមបណ្តឹងមានរយៈពេលតែ ០៦ខែ(ប្រាំមួយ)ប៉ុណ្ណោះ ដូច្នេះតុលាការគប្បីពិនិត្យ សម្រេចតាមសភាពជាក់ស្តែង ។

## ***ហេតុដូច្នេះសម្រេច***

**១-ផ្តន្ទាទោសជនជាប់ចោទ ៖** ឈ្មោះ [redacted] គីមសៀន ភេទប្រុស អាយុ ៣៦ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ០៦(ប្រាំមួយ) ខែ ។

ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិអូរមៀត សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] គីមសៀន បង់ថ្លៃឈ្នួលជួលគ្រឿងចក្រចំនួន ២៤,០០០ $ (ពីរម៉ឺនបួនពាន់)ដុល្លារអាមេរិក ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្តា ។ ការប្តឹងទាមទារលើសពីនេះលើកចោល ។

**៣-វត្ថុតាងរួមមាន៖** កាបូបយួរដៃចំនួន ០១ (មួយ) ពណ៌សូកូឡា, ទូរស័ព្ទដៃចំនួន ០១ (មួយ) ម៉ាក VIVO ពណ៌ខ្មៅលាយខៀវ, អត្តសញ្ញាណប័ណ្ណចំនួន ០១ (មួយ) សន្លឹក របស់ឈ្មោះ [redacted] គីមសៀន , កាតគ្រីម៉ូតូចំនួន ០១ (មួយ) សន្លឹក ផ្លាកលេខ កំពង់ធំ 1A-1499 កម្មសិទ្ធឈ្មោះ សូ ប៊ុនហុក និងកាតធនាគារអេស៊ីលីដាចំនួន ០១ (មួយ) សន្លឹក ឈ្មោះ SENG KOEHSEAN ប្រគល់ជូនម្ចាស់ដើមឈ្មោះ [redacted] គីមសៀន វិញ ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គីមសៀន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុចិន្តា ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned with CamScanner